**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០.វ.៩...សខ៧

# សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
## ស្តីពី
## វិធានការការពារការចម្លងវីរុសកូវីដ១៩ ចំពោះម្ចាស់រថយន្ត និងអ្នកធ្វើដំណើរ ដោយមធ្យោបាយដឹកជញ្ជូនរួម ដែលផ្ទុកអ្នកដំណើរច្រើនលើសពី ១០នាក់

ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត និងការចូលរួមការពារការចម្លងវីរុសកូវីដ១៩ របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន បន្ថែមលើវិធានការនានាដែលយើងទាំងអស់គ្នាបាននិងកំពុងតែអនុវត្ត ក្រសួងសុខាភិបាលសូមធ្វើការណែនាំដល់ម្ចាស់រថយន្ត និងអ្នកធ្វើដំណើរដោយមធ្យោបាយដឹកជញ្ជូនរួម (រថយន្ត Bus និង Mini bus) ដែលផ្ទុកអ្នកដំណើរច្រើនលើសពី ១០នាក់ ដូចខាងក្រោម៖

-បើកបង្អួចរថយន្ត ឲ្យខ្យល់ចេញ-ចូល (ដោយមិនប្រើម៉ាស៊ីនត្រជាក់)

-លើកទឹកចិត្តឲ្យអ្នកដំណើរពាក់ម៉ាស់ ឬក្រម៉ាខ្ទប់មាត់ ច្រមុះ ដើម្បីជៀសវាងការចម្លងជាយថាហេតុនៃវីរុសផ្តាសាយផ្សេងៗ រួមទាំងកូវីដ19 ផងដែរ

-ត្រូវសំអាតរថយន្តជាប្រចាំដោយប្រើទឹកសាប៊ូ និងជូតអាល់កុល តាមថ្នាក់កៅអី

-ម្ចាស់រថយន្តត្រូវមានទឹកអាល់កុល ឬជែលអាល់កុល ឲ្យអ្នកដំណើរលាងដៃ ពេលឡើងលើរថយន្ត

-ចំពោះអ្នកបើកបររថយន្តទាំងនោះ បើមានរោគសញ្ញា ដូចជា ផ្តាសាយ ត្រូវផ្អាកការបើកបរជាបណ្តោះអាសន្ន រួចអញ្ជើញទៅមន្ទីរពេទ្យសាធារណៈ ដើម្បីត្រួតពិនិត្យសុខភាព។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ ហើយក្រសួងក៏សូមអំពាវនាវដល់ម្ចាស់រថយន្ត និងអ្នកដំណើរទាំងអស់ សូមចូលរួមអនុវត្តតាមការណែនាំខាងលើនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីចូលរួមចំណែកកាត់ផ្តាច់ការចម្លងវីរុសកូវីដ១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ និងទៅសហគមន៍របស់យើង។

សេចក្តីណែនាំនេះមានប្រសិទ្ធភាព ចាប់ពីវេលាម៉ោង២៣:៥៩នាទី នៃថ្ងៃទី០៥ ខែមេសា ឆ្នាំ ២០២០ តទៅ។

ថ្ងៃអាទិត្យ ១៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល:**

-ក្រសួងសាធារណការ និងដឹកជញ្ជូន

-រដ្ឋបាលរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ